# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

<u>កិច្ចព្រមព្រៀង</u>

ស្តីពីការព្យួរកិច្ចសន្យាការងាររវាងតំណាងនិយោជិក នឹងក្រុមហ៊ុន អឺបៅអេស៊ា កាលពីថ្ងៃទី ២៣ ខែមិនា ឆ្នាំ២០២២ វេលាម៉ោង០៩ និង ០០នាទី មានការប្រជុំស្តីពីការព្យួរកិច្ចសន្យាការងារ នៅក្រុមហ៊ុន អឺបៅអេស៊ា មានទីតាំងនៅភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុង/ខេត្តសៀមរាប។

<u>សមាសភាពដែលចូលរួមក្នុងអង្គប្រជុំមាន:</u>

| <u>ក-ភាគីនិយោជក (តំណាងឲ្យក្រុមហ៊ុន)៖</u> | <u>តួនាទី</u> | <u>លេខទូរស័ព្ទទំនាក់ទំនង</u> |
|---|---|---|
| លោក ជា សេងហាក់ | ប្រធានផ្នែកធនធានមនុស្ស | 010777441 |

| <u>ខ-ភាគីនិយោជិក (តំណាងឲ្យបុគ្គលិក)៖</u> | <u>តួនាទី</u> | <u>លេខទូរស័ព្ទទំនាក់ទំនង</u> |
|---|---|---|
| កញ្ញា ឡុង ឆេងលាង | បុគ្គលិកផ្នែកលក់ | 010604247 |

ឆ្លងតាមការពិភាក្សាពន្យល់នូវគោលបំណងដែលពាក់ព័ន្ធនឹងការព្យួរឲ្យបានសមស្របតាមសេចក្តីណែនាំលេខ: ០៤៥/២០កប/ស.ណ.ន.ល ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រប់ភាគីទាំងពីរបានឯកភាពយល់ព្រមព្យួរកិច្ចសន្យាការងារចំពោះទាំងអស់ក្នុងរយៈពេល០២ខែ ដោយគិតចាប់ពី ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០២២ ដល់ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២ ដោយទទួលបាននូវទឹកប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗចំនួន៤០ដុល្លាអាមេរិកក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ។ សំរាប់ក្រុមហ៊ុន មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមទៅដល់បុគ្គលិកក្នុងពេលព្យួរកិច្ចសន្យាការងារនេះឡើយ ដោយសារតែក្រុមហ៊ុនទទួលរងផលប៉ះពាល់ដោយសារជំងឺ codvid-19 បាត់បង់ប្រាក់ចំណូល។

ការពិភាក្សានេះត្រូវបានបញ្ចប់នៅវេលាម៉ោង១១ និង ០០នាទី នាថ្ងៃទី ២៣ ខែមិនា ឆ្នាំ២០២២ដោយមានការចុះហត្ថលេខាព្រមព្រៀងរបស់តំណាងទាំងអស់ដែលអាចយកជាការបានចំពោះមុខច្បាប់។

កិច្ចព្រមព្រៀងខាងលើបង្ហាញពីពត៌មានពិត និងត្រឹមត្រូវរវាងភាគីដែលបានចុះហត្ថលេខាដូចខាងក្រោម:

| ភាគីនិយោជកតំណាងឲ្យនិយោជក | ភាគីតំណាងឲ្យនិយោជិក |
|---|---|
| ហត្ថលេខា/ស្នាមមេដៃ | ហត្ថលេខា/ស្នាមមេដៃ |
| អឺបៅ អេស៊ា ABOUT ASIA Co., Ltd. | |
| ជា សេងហាក់ | ឡុង ឆេងលាង |